តុលាការខេត្ត
សៀមរាប-ឧត្តរមានជ័យ
សាលក្រម
លេខ ៣៥ គ ចុះថ្ងៃទី ០២
ខែ ឧសភា ឆ្នាំ ២០០៦
សំណុំរឿងរដ្ឋប្បវេណី
លេខ ១៣២ ចុះថ្ងៃទី ២៥
ខែ មេសា ឆ្នាំ ២០០៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គោរពនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ**

បានបើកសវនាការជាសាធារណៈ នៅទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នាថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៦ ដោយមានសមាសភាព :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] ចៅក្រមតុលាការខេត្ត

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោកស្រី [redacted] ក្រឡាបញ្ជីតុលាការខេត្ត

ដើម្បីជំនុំជំរះរឿងរដ្ឋប្បវេណីលេខ ១៣២ ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៦ ។

**- ប្តឹងសុំលែងលះប្តី, សុំសិទ្ធិគ្រប់គ្រងកូន និង សុំបែងចែកទ្រព្យសម្បត្តិរួម ។**

រវាងដើមចោទឈ្មោះ **អ ខ្ម** ភេទស្រី អាយុ ២៦ឆ្នាំ ជាតិខ្មែរ របររកស៊ីនៅផ្ទះ ទីលំនៅភូមិស្វាយដង្គំ ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ **អ សអ** (ស) ម្តាយឈ្មោះ **អ ៤** ប្តីឈ្មោះ **ហ សរ** មានកូន ០២នាក់ ។

និងចុងចម្លើយឈ្មោះ **ហ សរ** ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិខ្មែរ របររកស៊ីមគ្គុទេសចរណ៍ ទីលំនៅ។ភូមិស្វាយដង្គំ ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ **ម លខ** (ស) ម្តាយឈ្មោះ **ទ ល** ប្រពន្ធឈ្មោះ **អ ខ្ម** មានកូន ០២ នាក់ ។

**<u>ដំណើររឿងមានដូចតទៅ</u>** :

តាមពាក្យបណ្តឹងចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៦ របស់ដើមចោទឈ្មោះ **អ ខ្ម** ប្តឹងសុំលែងលះពីចុងចម្លើយឈ្មោះ **ហ សរ** ដោយសំអាងហេតុថា ខ្លួនបានគ្នាជាប្តីប្រពន្ធតាំងពីឆ្នាំ ២០០០ មករហូតដល់ពេលនេះមានកូន ០២នាក់ ។ ថា ការរស់នៅធ្លាប់មានទំនាស់គ្នាជាញឹកញាប់ ដោយសារចុងចម្លើយបិទសិទ្ធិសេរីភាពខ្លួនគ្រប់បែបយ៉ាង សូម្បីតែប្រាក់ដែលរកចំណូលបានក៏ចុងចម្លើយមិនដែលអោយខ្លួនគ្រប់គ្រងដែរ ។ មូលហេតុទាំងនេះហើយដែលធ្វើអោយខ្លួនអស់មនោសញ្ចេតនាពីចុងចម្លើយ ។

**<u>នាពេលសវនាការ</u>**

ដើមចោទឈ្មោះ **អ ខ្ម** បានឆ្លើយថា នៅពេលនេះខ្លួននៅតែប្តឹងសុំលែងលះ

*សាលក្រមនេះចូលជាស្ថាពរចាប់ពីថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០៦*
*ដោយពុំមានភាគីណាមួយមកប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។*
*សៀមរាប.ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦*
**ក្រឡាបញ្ជី**
**ហត្ថលេខា និង ត្រា**
[redacted]

ពីចុងចម្លើយដដែល ដោយសំអាងហេតុថា តាំងពីខ្លួនរួមរស់ជាប្តីប្រពន្ធមក ប្តីខ្លួនធ្លាប់មានទំនាស់នឹងគ្នាជាញឹកញាប់ ទើបខ្លួនប្តឹងសុំលែងលះ កាលពីឆ្នាំ ២០០៤ រួចម្តងមកហើយ ហើយចៅក្រមអោយសះជានឹងគ្នាវិញ ហើយរស់នៅជាមួយគ្នារហូតដល់ឆ្នាំ ២០០៦ ខ្លួន និង ចុងចម្លើយនៅតែមានទំនាស់នឹងគ្នាទៀត ខ្លួនក៏ធ្វើពាក្យបណ្តឹងម្តងទៀត ដោយសារចុងចម្លើយបង្ករឿងហេតុមិនចេះចប់ព្រមទាំងបិទសិទ្ធិសេរីភាពខ្លួនគ្រប់យ៉ាង ។

កូន ០២នាក់ គឺកូនទី១ ឈ្មោះ **ទរស** ភេទស្រី អាយុ ០៥ឆ្នាំ និង កូនទី ០២ ឈ្មោះ **រស** ភេទស្រី អាយុ ០៣ឆ្នាំ ខ្លួនសុំសិទ្ធិគ្រប់គ្រង ។ ចំពោះប្រាក់អាហារកិច្ចចិញ្ចឹមកូនមិនទាមទារអោយចុងចម្លើយជួយចិញ្ចឹមទេ ។

ទ្រព្យសម្បត្តិរួមមានផ្ទះធ្វើអំពីថ្មប្រក់ស័ង្កសីទំហំ ៣.៥០ម៉ែត្រ គុណ ១២ម៉ែត្រ ដីបាតផ្ទះទំហំ ៣៩៩ម៉ែត្រ មានព្រំប្រទល់ខាងកើតទល់ផ្លូវ, ខាងលិចទល់ព្រំដីឈ្មោះ **ម សជ**, ខាងត្បូងទល់ព្រំដីឈ្មោះ **ហ លខ** និង ខាងជើងទល់ផ្លូវ ស្ថិតនៅភូមិស្វាយដង្គំ ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។ ថា [illegible] ផ្ទះនេះដាក់លក់បាន ប្រាក់ចែកគ្នាពាក់កណ្តាលម្នាក់ ដែលកំណត់តម្លៃ ២៥.០០០ដុល្លាអាមេរិក "ពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក" ទូរទស្សន៍ខ្នាត ២៤អ៊ិញ ០១គ្រឿងម៉ាកសូនី, ទូទឹកកក ០១គ្រឿង, គ្រែបេង ០២, ចង្ក្រានហ្គាស ០១, ក្បាលវីដេអែ ០១គ្រឿង ម៉ាកសូនិក, ទូតាំងទូរទស្សន៍ ០១, ម៉ូតូឌុនសេ១២៥ ផលិតឆ្នាំ ២០០៣ ពណ៌ខៀវ ០១គ្រឿង, តុបេង ០១, ទូដាក់ចាន ០១, ទូរស័ព្ទដៃម៉ាកណូគា ០១គ្រឿង, អាយកូម ០១គ្រឿង, ប្រាក់ **ហ ស** ជំពាក់ ៦៥០ដុល្លាអាមេរិក "ប្រាំមួយរយហាសិបដុល្លាអាមេរិក" សុំចែកគ្នាពាក់កណ្តាល តែប្រាក់ជំពាក់អង្គការអេស៊ីលីដាចំនួន ៤៦៦.៦២ដុល្លាអាមេរិក "បួនរយហាសិបប្រាំមួយ ដុល្លាហុកសិបពីរសេន" ខ្លួនសុំអោយចុងចម្លើយសងតែម្នាក់ឯងចុះ ។

ទ្រព្យសម្បត្តិរួមខ្លួនសុំសិទ្ធិគ្រប់គ្រង : ទូទឹកកក ០១គ្រឿង, គ្រែបេង ០១, ចង្ក្រានហ្គាស ០១, ទូតាំងទូរទស្សន៍ ០១, ទូដាក់ចាន ០១, ប្រាក់ **ហ ស** ជំពាក់ ៣២៥ដុល្លាអាមេរិក "បីរយម្ភៃប្រាំដុល្លាអាមេរិក" និង ប្រាក់លក់ដី និង ផ្ទះ បានចំណែកពាក់កណ្តាល ។

ទ្រព្យសម្បត្តិរួមប្រគល់អោយចុងចម្លើយគ្រប់គ្រងមាន : គ្រែបេង ០១, ទូរទស្សន៍ខ្នាត ២៤អ៊ិញ ម៉ាកសូនី ០១គ្រឿង, ក្បាលវីដេអែម៉ាកសូនិក ០១គ្រឿង, ម៉ូតូឌុនសេ ១២៥ ផលិតឆ្នាំ ២០០៣ ពណ៌ខៀវ ០១គ្រឿង, តុបេង ០១, ទូរស័ព្ទដៃម៉ាកណូគា ០១គ្រឿង, អាយកូម ០១គ្រឿង, ប្រាក់ **ហ ស** ជំពាក់ ៣២៥ដុល្លាអាមេរិក, ប្រាក់លក់ដី និង ផ្ទះ បានចំណែកពាក់កណ្តាលម្នាក់ តែអោយចុងចម្លើយសងប្រាក់អង្គការអេស៊ីលីដា ចំនួន ៤៦៦.៦២ ដុល្លាអាមេរិកតែម្នាក់ឯង ។

ចុងចម្លើយឈ្មោះ **ហ សរ** បានឆ្លើយថា នៅពេលនេះខ្លួនក៏យល់ព្រមលែងលះនឹងដើមចោទដែរ មូលហេតុតាំងពីខ្លួនរួមរស់នៅជាប្តីប្រពន្ធមក ដើមចោទនៅតែមិនទុកចិត្តខ្លួនតែពីបញ្ហាប្រាក់ដែលរកបានប្រចាំថ្ងៃថា ខ្លួនមានការលាក់លៀម តែតាមពិតខ្លួនកន្លងមក ខ្លួនខិតខំសន្សំប្រាក់រហូតបានផ្ទះនៅនេះ ក៏ជាប្រាក់ដែលខ្លួនខិតខំធ្វើការដែរ ។ ថា កន្លងមកខ្លួនមិនដែលមានចិត្តក្បត់ប្រពន្ធនោះទេ ។

កូន ០២នាក់ គឺកូនទី ១ ឈ្មោះ **ទរស** ភេទស្រី អាយុ ០៥ឆ្នាំ និង កូនទី ២ ឈ្មោះ **រស** ភេទស្រី អាយុ ០៣ឆ្នាំ ខ្លួនយល់ព្រមប្រគល់អោយដើមចោទពុំមានអ្វីជំទាស់ទេ ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា**

រឿងក្តីនេះជារឿងអាពាហ៍ពិពាហ៍លែងបានសំរេចដោយដើមចោទ និង ចុងចម្លើយអស់មនោសញ្ចេតនាពីគ្នាហើយ ។

គោលបំណងនៃអាពាហ៍ពិពាហ៍លែងបានសំរេច ដោយដើមចោទ និង ចុងចម្លើយអស់មនោសញ្ចេតនា

ពីគ្នាហើយ ។

ប៉ុន្តែទោះបីមានការលែងលះគ្នាក៏ដោយភាគីទាំងពីរមិនត្រូវទុកគ្នាជាសត្រូវឡើយ ។ ហើយឪពុកម្តាយមានកាតព្វកិច្ចអប់រំ ថែរក្សា ចិញ្ចឹមកូនតាមមាត្រា ៧៤ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

ហេតុនេះសូមតុលាការពិចារណាសំរេចតាមច្បាប់ចុះ ។

-បានស្តាប់ចម្លើយរបស់ដើមចោទឆ្លើយអោយការណ៍ និង ប្តឹងសុំ

-បានស្តាប់ចម្លើយរបស់ចុងចម្លើយ

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

**<u>តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ</u>**

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>យល់ឃើញថា</u>**

-ពាក្យបណ្តឹងរបស់ដើមចោទចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៦ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-គូភាគីជាប្តីប្រពន្ធមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។

-គូភាគីឯកភាពគ្នាលើការគ្រប់គ្រងកូន និង ប្រាក់អាហារកិច្ចចិញ្ចឹមកូន នោះតុលាការសំរេចតាមការព្រមព្រៀង ។

-គោលបំណងនៃអាពាហ៍ពិពាហ៍លែងបានសំរេច ដោយដើមចោទ និង ចុងចម្លើយអស់មនោសញ្ចេតនាពីគ្នាហើយ ។

**<u>ហេតុដូច្នេះ</u>**

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៦ របស់ដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-សំរេចឱ្យអ្នកស្រី **អ ១ជ** និង លោក **ហ សរ** លែងលះគ្នាចាប់ពីថ្ងៃនេះតទៅ ។ ដាក់កំហុសលើប្តី ។

៣-ឱ្យអ្នកស្រី **អ ណាល** ស្ថិតនៅភាពមេម៉ាយចំនួន ៣០០ថ្ងៃគិតចាប់ពីថ្ងៃនេះតទៅ ។

៤-កូន ០២នាក់ គឺកូនទី១ ឈ្មោះ **រ ទររស** ភេទស្រី អាយុ ០៥ឆ្នាំ និង កូនទី២ ឈ្មោះ **រ រស** ភេទស្រី អាយុ ០៣ឆ្នាំ ប្រគល់អោយដើមចោទគ្រប់គ្រង ។ តាមការព្រមព្រៀងរបស់គូភាគី ។
មាតាបិតាត្រូវមានសិទ្ធិ និង ករណីយកិច្ចអប់រំ ថែរក្សា ចិញ្ចឹមកូន តាមមាត្រា ៧៤ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

៥-ទុកសិទ្ធិអោយចុងចម្លើយទៅសួរសុខទុក្ខដល់កូនបាន ។

៦-ទ្រព្យសម្បត្តិរួម :

ក-ទូទឹកកក ០១គ្រឿង, គ្រែបេង ០១, ចង្រានហ្គាស ០១, ទូតាំងទូរទស្សន៍ ០១, ទូដាក់ចាន ០១, ប្រាក់

ប្រាក់ឈ្មោះ ហ ស ជំពាក់ ៣២៥ដុល្លាអាមេរិក "បីរយម្ភៃប្រាំដុល្លាអាមេរិក" ប្រគល់ឱ្យដើមចោទគ្រប់គ្រង ។

ខ-គ្រែបេង ០១, ទូរទស្សន៍ខ្នាត ២៤អ៊ីញម៉ាកសូនី ០១គ្រឿង, ក្បាលវីដេអែ ០១, ម៉ូតូធុនសេ ១២៥ ផលិតឆ្នាំ ២០០៣ ពណ៌ខៀវ ០១គ្រឿង, តុបេង ០១, ទូរស័ព្ទម៉ាកណូគា ០១គ្រឿង, ប្រាក់ឈ្មោះ ហ ស ជំពាក់ ៣២៥ដុល្លាអាមេរិក "បីរយម្ភៃប្រាំដុល្លាអាមេរិក" ប្រគល់អោយចុងចម្លើយគ្រប់គ្រង តែអោយចុងចម្លើយសងប្រាក់អេស៊ីលីដាចំនួន ៤៦៦,៦២ដុល្លាអាមេរិកតែម្នាក់ឯង ។

គ-ដីបាតផ្ទះទំហំ ៣៩៩ម៉ែត្រក្រឡាមានព្រំប្រទល់ខាងជើងទល់ផ្លូវ, ខាងលិចទល់ព្រំដីឈ្មោះ ម សជ ខាងត្បូងទល់ព្រំដីឈ្មោះ ហ លខ និង ខាងជើងទល់ផ្លូវ និង ផ្ទះទំហំ ៣.៥០ម៉ែត្រ គុណ ១២ម៉ែត្រ ធ្វើអំពីថ្ម ប្រក់ស័ង្កសី ស្ថិតនៅភូមិស្វាយដង្គំ, ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប លក់បាន ចែកគ្នាពាក់កណ្តាលម្នាក់ ។ តាមការព្រមព្រៀងរបស់គូភាគី ។

៧-សំរេចឱ្យលោក ហ សរ ជាចុងចម្លើយប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹង ១.៨០០រុ០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រុ០០ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រុ០០ បូករួម ៧.០០០រុ០០ ។ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រុ០០ ដែលដើមចោទបានបង់ទុករួចហើយ ។ កាលបើហួស ឧទ្ធរណ៍ បង្គាប់អោយចុងចម្លើយសងប្រាក់នេះទៅដើមចោទវិញ ។

៨-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់រយៈពេល ០២ខែគិត ចាប់ពីថ្ងៃនេះតទៅ ។

ក្រឡាបញ្ជីសវនាការ
ហត្ថលេខា និង ត្រា
[redacted]

ចៅក្រមជំនុំជំរះ
ហត្ថលេខា និង ត្រា
[redacted]